# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៥.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦/អនក្រ/បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រិត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃ ទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាលទៅជា អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

# ស ម្រេ ច

**មាត្រា១-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលមួយឈ្មោះថា មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងពត៌មានវិទ្យា ក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**មាត្រា២-**

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យមានភារកិច្ចៈ

-គ្រប់គ្រងផ្ទាល់នូវរាល់ទិន្នន័យសេវា ទូរគមនាគមន៍ និងពតិមានវិទ្យា គ្រប់ប្រភេទ និងសេវាថ្មីៗបន្ថែមទៀត ទៅតាមការវិវត្តន៍នៃបច្ចេកវិទ្យាលើវិស័យនេះ

-ដឹកនាំ គ្រប់គ្រងត្រួតពិនិត្យនូវរាល់សកម្មភាពការងាររួមទាំងអស់របស់ មជ្ឈមណ្ឌល

-រាយការណ៍ជាប្រចាំពីសភាពការណ៍ ត្រាហ្វិក ទិន្នន័យនានា ជូនដល់ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ផ្តល់តួលេខត្រាហ្វិក តួលេខចំណូល ដើម្បីជួយ សម្រួលដល់ការ កំណត់ពន្ធ និងអាករ និងការបែងចែកចំណូល រវាងរដ្ឋ និងដៃគូអាជីវកម្មសេវាទូរគមនាគមន៍ ពតិមានវិទ្យា និងរវាងប្រតិបត្តិករ និងប្រតិបត្តិករ ។

-ផ្តល់ទិន្នន័យត្រឹមត្រូវសម្រាប់ការព្យាករណ៍ប្រភពចំណូល ការវិភាគពីសក្តានុពលសេដ្ឋកិច្ច គំរោងវិនិយោគ និងអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍ និងពតិមានវិទ្យា

-ពង្រីក និងគ្រប់គ្រងបណ្តាញ "ត" ភ្ជាប់ (Interconnect Network) ដើម្បីធានាការចរាចរត្រាហ្វិកឆ្លងប្រព័ន្ធ (បញ្ចៀសការស្ទះត្រាហ្វិក) រវាងប្រព័ន្ធរបស់បណ្តាប្រតិបត្តិករទាំងអស់

-គាំទ្រដល់ប្រតិបត្តិករតូចៗ ឱ្យមានលទ្ធភាពធ្វើអាជីកម្ម តាមរយៈការបើកចំហរបណ្តាញហៅឆ្លងកាត់ប្រព័ន្ធ

-ផ្តាច់ចោលនូវត្រាហ្វិកខុសច្បាប់ តាមបញ្ជាសមត្ថកិច្ចនិយ័តកម្មទូរគមនាគមន៍

-បង្កើតបណ្តាញផ្ទៀងផ្ទាត់ពេលវេលាគោលមួយ (Master Clock ) សំរាប់បណ្តាប្រតិបត្តិករទាំងអស់ ។

**មាត្រា៣-**

គ្រប់បណ្តាប្រតិបត្តិករផ្តល់សេវា ទូរស័ព្ទគ្រប់ប្រភេទ មាត់ច្រកទូរគមនាគមន៍អន្តរជាតិ អ៊ិនទែរណែត និងប្រតិបត្តិករសេវាថ្មីៗទៀតដែលទទួលអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នោះ ត្រូវផ្តល់នូវ **CDR** (Call Details Record ) មកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យតាមរយៈការភ្ជាប់បណ្តាញផ្ទាល់ **( Direct Links )** ដើម្បីឱ្យការស្រង់ទិន្នន័យរហ័សបានទាន់ពេលវេលា ក្នុងករណីបណ្តាញ

ភ្ជាប់គ្រង់មានបញ្ហាបច្ចេកទេសនោះ គ្រប់ប្រតិបត្តិករទាំងអស់ត្រូវផ្តល់ CDRដើម ( Raw CDR) មកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ ដោយស្វ័យប្រវត្តិ ។

**មាត្រា៤ -**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវមានកិច្ចសន្យាដោយឡែកជាមួយក្រុមហ៊ុន **ដាតា មេនេចមេន សេនធ័រ** តាមទម្រង់ កិច្ចសន្យាសហការ សំរាប់ដំណើរការមជ្ឈមណ្ឌលដែលមានចែងក្នុងមាត្រា១ ។

**មាត្រា៥ -**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់ប្រតិបត្តិករនៃទូរស័ព្ទ ទូរគមនាគមន៍ និង ពត៌មានវិទ្យាគ្រប់ប្រភេទ មាត់ច្រកទូរគមនាគមន៍អន្តរជាតិទាំងអស់ និងប្រតិបត្តិករសេវាថ្មីៗទៀត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**មាត្រា៧ -**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ